UNITED NATIONS/ NATIONS UNIES
SPECIAL REPRESENTATIVE OF THE SECRETARY GENERAL
FOR HUMAN RIGHTS IN CAMBODIA/
REPRESENTANT SPECIAL DU SECRETAIRE GENERAL
POUR LES DROITS DE L'HOMME AU CAMBODGE

---

# ការចងពៀរគ្នាតាមដងផ្លូវ នៅក្នុងប្រទេសកម្ពុជា

នៅក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួន ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នាពេលថ្មី ៗ នេះ គណៈកម្មការសិទ្ធិមនុស្សបានលើកឡើងជាថ្មីម្តងទៀត នូវសេចក្តីព្រួយបារម្ភស្តីពីការខ្វះខាតជាក់ស្តែង ក្នុងការការពារកុំឱ្យមានការសម្លាប់មនុស្សដោយហ្វូងមហាជន ។ នេះគឺជាបញ្ហាមួយ ដែលលោកតំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានទាញការចាប់អារម្មណ៍ នៅក្នុងរបាយការណ៍ជាបន្តបន្ទាប់របស់លោក ។ នៅក្នុងពេលនេះ លោកសូមអំពាវនាវជាថ្មីម្តងទៀត សូមឱ្យចាត់ឱ្យមានវិធានការ និងការទប់ស្កាត់ ប្រកបដោយប្រសិទ្ធភាព ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានចងក្រងជាឯកសារនូវករណីនៃការ រំលោភ និងការសម្លាប់ដោយហ្វូងមហាជន ចំនួនប្រមាណ ៦៥ ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៩៩ មក ។ ទិសដៅនៃឯកសារសង្ខេបនេះ គឺផ្តល់ពត៌មានបន្ថែម ស្តីពីបញ្ហានេះ និងដើម្បីផ្តល់យោបល់លើការដោះស្រាយប្រកបដោយប្រសិទ្ធភាព ដើម្បីជួយដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចខិតខំរបស់ខ្លួនដើម្បីបញ្ចប់នូវអំពើហឹង្សាបែបនេះ។ មានការកើនឡើងយ៉ាងរហ័សនូវឧប្បត្តិហេតុនៃអំពើហឹង្សាដោយហ្វូងមហាជន បន្ទាប់ពីការនេះបានថយចុះមួយឆ្នាំកន្លះ និងនៅក្នុងពេលដែលប្រទេសកំពុងរៀបចំការបោះឆ្នោតទូទៅ នៅឆ្នាំក្រោយនេះ ។ ក្នុងរយៈពេល ៦ ខែ គិតមកទល់ដំណាច់ខែឧសភា ឆ្នាំ ២00២ នេះ ហ្វូងមនុស្សដែលមានកំហឹង បានសម្លាប់ និងធ្វើឱ្យពិការ ចនួន ១១ លើក ប្រៀបធៀបទៅនឹងឧប្បត្តិហេតុបែបនេះដែលបានកើតមានឡើងតែចំនួន ៣ លើកប៉ុណ្ណោះ កាលពី ៦ ខែមុននោះទៅទៀត ។ នេះគឺជាការវិវត្តន៍មួយ ដែលគួរឱ្យព្រួយបារម្ភ ។

ជាញយ ៗ សមាជិកកងកម្លាំងនគរបាលកម្ពុជា តែងតែខកខានមិនបានអន្តរគមន៏និងបានចូលរួមដោយផ្ទាល់ នៅក្នុងឱកាសជាច្រើន ។ ក៏ប៉ុន្តែ នៅក្នុងឆ្នាំកន្លងទៅនេះ ក៏បានឃើញផងដែរថាមានឱកាសខ្លះ ដែលបានដឹងជាលើកទី ១ ដែលកងនគរបាលបានអន្តរាគមន៏ដោយជោគជ័យ ដើម្បីបញ្ឈប់កំឱ្យមានការកាប់សម្លាប់មនុស្ស ។ ក្នុងចំណោមមនុស្ស ៦ នាក់ ដែលបានរស់រានមានជីវិតពីការវាយ

ប្រហារដោយហ្វូងមហាជន មាន ៥ នាក់បានរួចពីស្លាប់ដោយសារអន្តរគមន៍របស់កងនគរបាល ។ ការណ៍នេះ គឺជាការគួរឱ្យលើកទឹកចិត្តបំផុត តែមានសេចក្តីត្រូវការលើសពីនេះទៅទៀត ។

ការប៉ុនប៉ងជាច្រើន ត្រូវបានធ្វើឡើងជាច្រើនឆ្នាំមកហើយ ដើម្បីពន្យល់អំពីមូលហេតុនៃអំពើហឹង្សាដោយហ្វូងមហាជន នៅក្នុងប្រទេសកម្ពុជា ។ ហេតុផលដែលបានផ្តល់ជាទូទៅ គឺសីលធម៌ និងការអប់រំកិរិតទាប ក្នុងចំណោមប្រជាពលរដ្ឋ ដែលទើបនឹងងើបពីការឈឺចុកចាប់នៃសង្គ្រាម និងអវត្តមានដ៏រីករាលដាលនៃជំនឿលើប្រព័ន្ធព្រហ្មទណ្ឌ និងតុលាការ ។ ប៉ុន្តែ មូលហេតុនានាមានភាពស្មុគ្រស្មាញជាងនេះយ៉ាងច្បាស់ និងតម្រូវឱ្យមានការយល់កាន់តែល្អជាងនេះថែមទៀត បើសិនជាចង់រកឱ្យឃើញនូវការដោះស្រាយដោយសព្វមុខនោះ។ គឺដោយសារហេតុនេះហើយ ដែលលោកតំណាងពិសេស បានផ្តល់ជាអនុសាសន៍នៅក្នុងរបាយការណ៍នេះ ឱ្យមានការបង្កើតឡើងនូវគណៈកម្មការសើបអង្កេតឯករាជ្យមួយ ដើម្បីធ្វើការវាយតម្លៃថាតើហេតុអ្វីបានជាការវាយប្រហារបែបនេះកើតមាន និងថាតើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីទប់ស្កាត់កុំឱ្យវាកើតមានឡើងបាន ។

## ឧស្សន៍នូវនោះ

កាសែតជាតិកម្ពុជា បានកត់ត្រាឃើញយ៉ាងតិចណាស់ចំនួន ៦៥ នៃករណីនៃការសម្លាប់ និងការវាយប្រហារដោយហ្វូងមនុស្សដែលមានកំហឹង ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៩៩ មក នៅពេលដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានចាប់ផ្តើមកត់ត្រា និងស៊ើបអង្កេតឧប្បត្តិហេតុបែបនេះ ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលសិទ្ធិមនុស្សជាតិនានា ។ ករណីទាំងនេះច្រើនតែប្រមូលផ្តុំ នៅក្នុងទីក្រុង ។ ករណីជិត ៥០ បានកើតមានឡើងនៅក្នុងទីក្រុងភ្នំពេញ ។

សង្វាក់នៃឧប្បត្តិហេតុបែបនេះ មានការប្រែប្រួលដូចដែលបង្ហាញឱ្យឃើញនៅក្នុងតារាងខាងក្រោមនេះ។ ជាងពាក់កណ្តាលនៃការវាយប្រហារទាំងអស់ បានកើតឡើងក្នុងរយៈពេល ៩ ខែ គិតមកទល់ខែមីនា ឆ្នាំ ២០០០ ។ រយៈពេលដ៏ខ្លាំងក្លា នៃអំពើហឹង្សារបស់ហ្វូងមហាជន បានកើតមានបន្ទាប់ពីក្រសួងមហាផ្ទៃចេញសេចក្តីណែនាំមួយ កាលពីខែឧសភា ឆ្នាំ ១៩៩៩ អនុញ្ញាតឱ្យបង្កើតក្រុមសន្តិសុខប្រជាពលរដ្ឋ នៅក្នុងទីក្រុងភ្នំពេញ និងនៅទីកន្លែងដ៏ទៃទៀត ដែលត្រូវបានស្គាល់ថាជាកម្លាំងនៃចលនាស្វ័យការពារ ។ ទោះបីជាពុំមានចំណងជាភស្តុតាងជាក់ស្តែង ឬដោយផ្ទាល់ក៏ដោយ ក៏លោកតំណាងពិសេសយល់ឃើញថា ហេតុផលនៃការដាក់បញ្ចូល និងការផ្សព្វផ្សាយវិធានការមួយបែបនេះ នៅក្នុងបរិយាកាសមួយដែលអំពើហឹង្សាបានកើតមានមកហើយនោះ ត្រូវបានកំណត់ថាជាការមិនត្រឹមត្រូវ ។ សេចក្តីណែនាំនេះ មិនបានលប់ចោលទៅវិញទេ តែហាក់ដូចជាត្រូវផ្អាកទៅវិញ បណ្តាលមកពីបញ្ហានៃការអនុវត្តន៍ ។

**ការវាយប្រហារដោយហ្វូងមហាជនៈ ពីខែឧសភា ឆ្នាំ ១៩៩៩ ដល់ខែមិថុនា ឆ្នាំ ២០០២**




នៅក្នុងឱកាសខ្លះ វិធានការរបស់អាជ្ញាធរក៏បានដើរតួនាទីជាវិជ្ជមានផងដែរ ។ នៅថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២000 ឯកឧត្តម ជា សុផារ៉ា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ បានចេញសេចក្តីណែនាំឱ្យ ទប់អំពើហឹង្សាដោយហ្វូងមហាជន និងអំពាវនាវសូមឱ្យអាជ្ញាធរតុលាការដើរតួនាទីក្នុងការដោះស្រាយជាមួយប្រជាពលរដ្ឋតាមផ្លូវច្បាប់ ។ គ្រាន់តែក្នុងរយៈប៉ុន្មានអាទិត្យប៉ុណ្ណោះ ឧប្បត្តិហេតុនៃហ្វូងមហាជនបានធ្លាក់ចុះមកក្រោម មួយករណីក្នុងមួយខែ ពីមធ្យមភាគ ៤ ករណីក្នុងមួយខែកាលពីពេលមុន ។ ទោះបីជាមូលហេតុដ៏ទៃទៀតនៃការថយចុះនេះ មិនអាចបដិសេធបានក៏ដោយ ក៏ហាក់ដូចជាថាការបង្ហាញឱ្យឃើញនូវសេចក្តីប្តេជ្ញាចិត្តផ្នែកនយោបាយបែបនេះ មានបច្ច័យដ៏មានតម្លៃមួយដែរ ។

ប៉ុន្តែ ក្នុងរយៈ ៦ ខែកន្លងទៅនេះ អត្រាបានកើនឡើងជាថ្មីឡើងវិញ ។ ការវាយប្រហារដោយហ្វូងមហាជនកំពុងកើតមានឡើងជាមធ្យម ២ ក្នុងមួយខែ ។ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២00១ កូនសិស្ស ២ នាក់ ត្រូវ បានវាយរហូតដល់ស្លាប់នៅក្នុងទីក្រុងភ្នំពេញ ហើយសិស្សម្នាក់ទៀតត្រូវរបួស បន្ទាប់ពីឪពុកម្តាយនៃសិស្សរួមថ្នាក់ផ្តន្ទាទោសពួកគេដោយស្រែកជាសាធារណៈថា " ចាប់ ចោរ" ។ នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២00២ ករណីដែលបានដឹងជាលើកដំបូងនៃការវាយប្រហារដោយហ្វូងមហាជនមួយ នៅក្នុងអតីតដំបន់ខ្មែរក្រហម មនុស្ស ២ នាក់ ត្រូវបានអូសចេញពីដៃនគរបាល ដែលកំពុងតែនាំខ្លួនពួកគេពីប៉ៃលិន ទៅកាន់បាត់ដំបង និងបានវាយរហូតដល់ស្លាប់ដោយហ្វូងមហាជនដែលកំពុងរង់ចាំ ។ នៅថ្ងៃទី ២១ ខែមីនា ឆ្នាំ ២00២ ឈ្មោះ ឡេង រតនៈ ជានិស្សិតវិជ្ជាស្ថានជាតិគ្រប់គ្រង ត្រូវបានរងការវាយដំយ៉ាងធ្ងន់ធ្ងរ បន្ទាប់ពីហ្វូងមហាជនត្រូវបានប្រាប់ឱ្យដឹងថារូបគេជាចោរនោះ ។ គេត្រូវបានរួចជីវិតដោយអន្តរាគមន៍ របស់នគរបាល ។

## អំពើហិង្សានៃហ្វូងមហាជន និងប្រព័ន្ធផ្សព្វផ្សាយពត៌មាន

ការវាយប្រហារដោយហ្វូងមហាជន ត្រូវបានផ្តល់នូវឯកសារដ៏ល្អដោយសារពតិមានជាតិ និងអន្តរជាតិ ដោយពេលខ្លះពួកគេហៅថាជាតុលាការប្រជាជន ។ កិច្ចខិតខំដាច់ខាតរបស់បុគ្គលខ្លះ ដើម្បីធ្វើអន្តរាគមន៏ នៅពេលខ្លះ បានផ្តល់នូវប្រសិទ្ធភាពដែរ ។ ឧទាហរណ៏ នៅខែមេសា ឆ្នាំ ២០០០ របាយការណ៏មួយនៅក្នុងកាសែតញ៉ូវយកថែម បានរៀបរាប់អំពីថាតើជនជាតិបារាំងម្នាក់ ឈ្មោះ អូលីវីយេ ដឺ ប៉ែកណុង បានប្រឈមមុខនឹងហ្វូងមហាជនដែលបានទាត់ធាក់ និងដាល់យុវជនម្នាក់ ដែលត្រូវជាប់ចោទថាបានលួចម៉ូតូ យ៉ាងដូចម្តេច ហើយបន្ទាប់មកបានទប់ទល់ នឹងហ្វូងមហាជនអស់រយៈពេល ២ ម៉ោង រហូតដល់រថយន្តពេទ្យបានមកដល់ ។ ជាការគួរឱ្យសោកស្តាយ ដោយសារថាអន្តរគមន៏បែបនេះមានតិចតួចស្តួចស្តើងណាស់ ។

សមាជិកកងនគរបាល និងអ្នកដ៏ទៃទៀត ដែលមានអំណាច ឬឥទ្ធិពល ធ្វើអន្តរាគមន៏ដោយកម្រណាស់ (សូមអានផ្នែកតទៅនេះ) ហើយពេលខ្លះថែមទាំងចូលរួមដោយផ្ទាល់ទៀតផង ។ ឧទាហរណ៏ នៅក្នុងឧប្បត្តិហេតុ ដឺប៉ែណុង នាយនគរបាលប្រមាណជាង ១០ នាក់ អង្គុយមើលដោយអកម្ម ដូចលោកសង្ឃមួយចំនួនដែរ ។ នៅក្នុងឧប្បត្តិហេតុមួយទៀត កាលពីថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៩ និងផ្តល់ជាឯកសារនៅក្នុងរបាយការណ៏មួយចុះផ្សាយក្នុងកាសែត " ភ្នំពេញប៉ុស្តិ៍" ឈ្មោះ សេង វណ្ណៈ នាយនគរបាលថ្នាក់ខ្ពស់ម្នាក់ នៃខ័ណ្ឌចំការមន ក្រុងភ្នំពេញ បាននាំខ្លួនជនសង្ស័យម្នាក់ពីស្ថានីយ ដោយដោះខ្នោះដៃចេញ រួចប្រគល់រូបគេទៅឱ្យហ្វូងមហាជនមួយក្រុមដែលកំពុងរង់ចាំ ។ មនុស្សនោះ បានស្លាប់ក្នុងពេលប៉ុន្មាននាទីក្រោយមក ។ លោកតំណាងពិសេសបានដឹងថា ពុំមានវិធានការវិន័យ ឬ ព្រហ្មទ័ណ្ឌណាមួយត្រូវចាត់ឱ្យមានឡើងក្នុងករណីនេះទេ ។

ការវាយប្រហារដោយហ្វូងមហាជនភាគច្រើនលើសលប់ តែងតែកើតយ៉ាងរហ័សបំផុត ដោយជនរងគ្រោះ ស្ទើរតែទាំងអស់ពុំមានឱកាសបញ្ជាក់ពីភាពស្មោះត្រង់របស់គ្នាឡើយ ។ ត្រឹមតែការចោទប្រកាន់ដ៏សាមញ្ញមួយ ហាក់ដូចជាគ្រប់គ្រាន់ ដូចជាឱ្យប្បត្តិហេតុនៃការស្រែក " ចាប់ចោរ" ខាងលើ បានបង្ហាញឱ្យឃើញស្រាប់ ។ អំពើហឹង្សាអាចប្រព្រឹត្តទៅលើមនុស្សសឹងតែទាំងអស់ មិនថាមនុស្សនោះត្រូវបានហ្វូងមហាជនស្គាល់ ឬមិនស្គាល់នោះទេ។ នៅក្នុងពេលបោះឆ្នោត ឆ្នាំ ១៩៩៨ យ៉ាងហោចណាស់ជនជាតិវៀតណាមចំនួន ៣ នាក់ រស់នៅក្នុងទីក្រុងភ្នំពេញ ត្រូវបានគប់នឹងដុំថ្មរហូតដល់ស្លាប់ និងអ្នកដ៏ទៃទៀត ត្រូវបានវាយដំ នៅដែលមានពាក្យចចាមអារ៉ាមថា ចំណីអាហារ និងទឹក នៅក្នុងទីក្រុងមានដាក់ថ្នាំពុល ។ នៅពេលខ្លះទៀត ហ្វូងមហាជនបានប្រព្រឹត្តរហូតសឹងតែបណ្តាលឱ្យមានកើតប្បត្តិហេតុអន្តរជាតិទៀតផង ។ នៅក្នុងខែមីនា ឆ្នាំ ២០០១ ទីភ្នាក់ងារពតិមានអាល្លឺម៉ង់ ឈ្មោះ " ដឺតប្រែសអាហ្សង់ទារ" បានរាយការណ៏ថា ទេសចរណ៏ថៃមួយក្រុមកំពុងទស្សនាអង្គរវត្ត ត្រូវការពារដោយនគរបាលត្រឡប់ទៅឆ្លងព្រំដែនវិញ បន្ទាប់ពីកំហឹងមួយបានផ្ទុះឡើង ក្នុងហ្វូងមហាជន នៅពេលពួកគេបាន គប់បង្អែមទៅលើអ្នកសុំទាន និងក្មេង ៗ ។

## អន្តរាគមន៍របស់កងនគរបាល និងឆ្លើយតបរបស់តុលាការ

ការវិវត្តន៍ជាវិជ្ជមានមួយកាលពីខែថ្មី ៧ កន្លងទៅនេះ គឺជាលើកទី ១ ហើយ ដែលកងនគរបាលបានបង្ហាញឱ្យឃើញឆន្ទៈខ្លះនៃការធ្វើអន្តរាគមន៍របស់ពួកគេ ។ ឧទាហរណ៍ទី ១ ដែលការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានដឹង បានកើតមាននៅក្នុងខែមីនា ឆ្នាំ ២០០១ ដោយកងនគរបាលបានផ្តល់កិច្ចការពារដល់យុវជនចំនួន ៥ នាក់ (ដែលក្រោយមកត្រូវបានដឹងតាមរយៈកាសែតថាជាកូនរបស់មន្ត្រីក្រសួងមហាផ្ទៃ) ដែលត្រូវបានដេញចាប់ដោយហ្វូងមហាជន បន្ទាប់ពីពួកនេះបានលួចខ្សែ-ក គេ ។ អន្តរាគមន៍របស់កងនគរបាល កាលពីថ្ងៃ ទី ២១ ខែមីនា ឆ្នាំ ២០០២ ប្រាកដជាបានជួយជីវិតនៃនិស្សិតអាយុ ២០ ឆ្នាំ នៅភ្នំពេញម្នាក់ឈ្មោះ ឡេង រតនៈ (ដូចដែលបានលើកឡើងខាងលើ) ។ អន្តរាគមន៍ដូចគ្នានេះ បានកើតមានឡើងនៅថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០០២ បន្ទាប់ពីមនុស្ស ២ នាក់ ដែលត្រូវបានចោទប្រកាន់ថាបានលួចម៉ូតូគេ ឈ្មោះ ញៀម ញ៉ាញ់ និងឱម គិមហ៊ុន ហើយកំពុងត្រូវវាយប្រហារដោយហ្វូងមហាជន ។

ការវិវត្តន៍ជាវិជ្ជមានទាំងនេះ ត្រូវធ្វើជាបន្តទៅទៀត។ គួរឱ្យសោកស្តាយ ដោយការនេះបានកើតមានដោយរប៉េះរប៉ោះប៉ុណ្ណោះ ។ ការផ្សាយនៅក្នុងកាសែតនូវឧប្បត្តិហេតុ ក្នុងរយៈពេលជាង ៣ ឆ្នាំ កន្លងទៅនេះ ក៏ដូចជាការងាររបស់អង្គការសិទ្ធិមនុស្សនានា បានកត់ត្រាករណីជាច្រើនដែលកងនគរបាល ឬអ្នកមុខអ្នកការដ៏ទៃទៀតនៃអាជ្ញាធរ បានបដិសេធមិនជួយប្រជាពលរដ្ឋ ដែលត្រូវសម្លាប់ ឬបានចូលរួមចំណែកដោយសកម្មអុជអាលឱ្យមានអំពើហឹង្សាដោយហ្វូងមហាជន ។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានធ្វើការស៊ើបអង្កេតដោយហ្មត់ចត់ ជាមួយអង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាលជាតិ ចំពោះករណីចំនួន ១៩ នៃការវាយប្រហារ ដោយហ្វូងមហាជន ដែលបានកើតមានឡើងនៅក្នុងរយៈពេលជាង ៣ ឆ្នាំ កន្លងទៅនេះ ។ ភស្តុតាងនៃការមិនខ្វល់ជាមួយ ឬការចូលរួមគំនិត ត្រូវបានរកឃើញមាននៅក្នុងករណី ចំនួន ៣ នៃករណីទាំងនេះ ។ ព្រឹត្តិការណ៍បែបនេះជាច្រើន ត្រូវថតជារូបភាពបាន ដែលបង្ហាញឱ្យឃើញស្លាកស្នាមសំគាល់ ស្បែកជើង ខោ និងកាំភ្លើង និងពេលខ្លះ មុខមាត់របស់នាយនគរបាលដែលមានវត្តមាននៅទីនោះផង ។ ឧទាហរណ៍បែបនេះមួយ (សូមអានឧបសម្ព័ន្ធផង) បានកើតមានឡើងនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០ នៅក្នុងទីក្រុងភ្នំពេញ នៅពេលដែលយុវជន ២ នាក់ ឈ្មោះ សុង វាសនា និង ឌី ហោ ត្រូវបានចាប់ខ្លួនពីការជាប់សង្ស័យពីការប្លន់ ។ វាសនា ត្រូវបាននាំខ្លួនទៅកាន់ស្ថានីយនគរបាល ខណ្ឌ ៧ មករា ដើម្បីសួរចម្លើយ ។ មួយសន្ទុះក្រោយមក រូបគេត្រូវនាំទៅកាន់កន្លែងចាប់ខ្លួនវិញ ហើយត្រូវបានប្រគល់ទៅឱ្យហ្វូងមហាជន ។ រូបគេត្រូវបានវាយដំរហូតដល់ស្លាប់ ហើយសាកសពរបស់គេត្រូវបានដុតថែមទៀត ។ ឈ្មោះ ឌី ហោ ត្រូវបាននាំទៅឆ្ងាយដោយឡែក ហើយត្រូវនគរបាលបាញ់សម្លាប់ ដោយនគរបាលបាននិយាយថារូបគេប៉ុនប៉ងរត់ ។ តាមលោកតំណាងពិសេសបានដឹង ពុំមានវិធានការវិន័យ ត្រូវបានធ្វើឡើងចំពោះករណីនេះ និងករណីដ៏ទៃទៀតឡើយ ។

វិសាលភាពរបស់របាយការណ៍របស់កងនគរបាល ស្តីពីការសម្លាប់ដោយហ្វូងមហាជន បានធ្វើ និងបានបញ្ជូន ទៅកាន់តុលាការសំរាប់ចាត់វិធានការ មានភាពមិនច្បាស់លាស់ (មន្ត្រីតុលាការ ជារឿយ ៗ តែងនិយាយ ថា ពួកគេមិនបានទទួលសំណុំរឿងពីនគរបាលទេ ឧទាហរណ៍ រួមទាំងករណី សុង វាសនាផង)។ នេះគឺជាការគួរឱ្យព្រួយបារម្ភ ដោយវាផ្តល់ឱកាសឱ្យតុលាការ និងនគរបាល ឆ្លើយដាក់គ្នា

ទៅវិញទៅមក ចំពោះថាតើអ្នកណាជាអ្នកទទួលខុសត្រូវ ចំពោះការខកខានមិនបានអនុវត្តន៍ច្បាប់ ។ មានតែករណីចំនួន ២ ប៉ុណ្ណោះ ដែលការិយាល័យឧត្តមស្នងការបានដឹង ដែលតុលាការបានយកករណីមកពិនិត្យ (ក្នុងនេះទៀត មិនទាន់មានអ្នកណាមួយត្រូវបានដាក់ឱ្យជាប់ឃុំ នៅឡើយទេ) ។ ករណីទាំងនេះ ពាក់ព័ន្ធនឹងការកាត់ទោសដោយកំបាំងមុខ មនុស្សម្នាក់ពាក់ព័ន្ធនឹងការសម្លាប់ឈ្មោះ អី សារឿន កាលពីថ្ងៃទី ៤ ខែមករា ឆ្នាំ ២០០០ នៅក្នុងស្រុកកំពង់រោ ខេត្តស្វាយរៀង (ដែលត្រូវបានចោទប្រកាន់ដោយច្រឡំថាជាចោរប្លន់ បន្ទាប់ពីមានជម្ងឺ ហើយវង្វេងចូលទៅក្នុងភូមិមួយមិនធ្លាប់ស្គាល់ នៅតាមផ្លូវទៅកាន់ទីក្រុងព្រះសីហនុ) ហើយនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០១ ការវាយសម្លាប់កូនសិស្សសាលា ២ នាក់ ដែលបានលើកឡើងខាងលើ ។ ក្នុងករណីចុងក្រោយនេះ ឪពុកម្តាយនៃសិស្សរួមថ្នាក់ដែលបានសំឡុតគេនោះ ត្រូវបានឃុំខ្លួនពីដំបូង ព្រមជាមួយក្មេង ៧ ដែលនៅរស់នៅឡើយ ។ ក្មេងរងគ្រោះ ត្រូវបានដោះលែងនៅថ្ងៃទី ៥ ខមីនា ឆ្នាំ ២០០២ ។ រហូតដល់ចុងខែឧសភា ឪពុកម្តាយនៅជាប់ឃុំនៅឡើយ រង់ចាំការកាត់ទោស ។

## នយោបាយលើកទឹកចិត្ត/មិនលើកទឹកចិត្តឱ្យមានអំពើហិង្សាដោយហ្វូងមហាជន

បញ្ហានៃការសំលាប់ដោយហ្វូងមហាជននៅក្នុងប្រទេសកម្ពុជាជាច្រើនឆ្នាំកន្លងមកនេះ ត្រូវបានចាត់ទុកថាជានិទណ្ឌភាព ដែលបានកើតចេញ មកប្រព័ន្ធយុត្តិធមិ និងព្រហ្មទណ្ឌមិនដំណើរការ និងមានទំនោរទៅរកអំពើពុករលួយ និងការជ្រៀតជ្រែកពីខាងនយោបាយ ឬក៏ពីកត្តាខាងក្រៅផ្សេងទៀត ។ ទោះជាមូលហេតុអ្វីក៏ដោយ កាលៈទេសៈដែលធ្វើអោយកើនឡើងនូវអំពើហឹង្សាដោយហ្វូងមហាជន បានចេញមកពី មូលហេតុជាក់លាក់ដ៏ទៃទៀត :

មូលហេតុចម្បងក្នុងចំណោមនោះ មានការជឿជាក់មួយដែលថា យុត្តិធមិហ្វូងមហាជនត្រូវបានបណ្តោយអោយមាន ឬក៏លើសពីនេះ ត្រូវបានជូនជារង្វាន់ថែមទៀត ។ ជាឧទាហរណ៍ នៅថ្ងៃទី ៨ ខែ មិនា ឆ្នាំ ២០០០ សុង តាំ ជាជនជាតិភាគតិចវៀតណាម និងជាកម្មករសំណង់ត្រូវបានវាយដោយប៉ូលិស និងបន្ទាប់មកត្រូវបានប្រគល់អោយទៅហ្វូងមហាជនដែលបានសំលាប់គាត់ ដោយសារតែគាត់មានគោលបំណងលួចម៉ូតូគិតទុកជាមុន ។ បន្ទាប់មកសមាជិកនៃក្រុមហ្វូងមហាជន បានប្រាប់អ្នកស៊ើបអង្កេតការងារសិទ្ធិមនុស្សថា ប៉ូលិសបានបដិសេធប្រគល់រង្វាន់ដែលគេទាមទារនោះពីអាជ្ញាធរក្រុងដែលមានទឹកប្រាក់ចំនួន មួយលានរៀលសំរាប់សំលាប់ចោរប្លន់ម្នាក់ ។ ការស្នើសុំរង្វាន់ដូចគ្នានេះដែរ ត្រូវបានទាមទារដោយហ្វូងមហាជនមួយក្រុមនៅថ្ងៃទី ២១ មិនា ឆ្នាំ ២០០០ ក្នុងការសំលាប់ ណុប ហុង អាយុ ៣៨ ឆ្នាំ ជាកម្មករដែលត្រូវបានច្រឡំថាជាចោរ បន្ទាប់ពីបានវង្វេងនៅក្នុងភូមិមួយដែលគាត់មិនស្គាល់ និងបន្ទាប់ពីគាត់សុំទឹកមួយកែវ ។ ការទាមទាររង្វាន់នេះត្រូវបានលុបចោលវិញ នៅពេលដែលដឹងថា មនុស្សគ្មានទោសម្នាក់ត្រូវបានសំលាប់ ។

ការរំពឹងចង់បានរង្វាន់បែបនេះជាគោលគំនិតទូទៅដែលយល់ថា ការសំលាប់មនុស្សអាក្រក់ម្នាក់ ត្រូវបានគេទទួលស្គាល់ បណ្តោយអោយមាន និងត្រឹមត្រូវ ។ ការទាំងនេះត្រូវបានកើតរិតតែខ្លាំងឡើង នៅពេលដែលសមាជិកនៃកងកំលាំងប៉ូលិសកម្ពុជាបានពាក់ព័ន្ធ ដោយផ្ទាល់ក្នុងការប្រគល់មនុស្សអោយទៅហ្វូងមហាជន ជាជំនួសក្នុងការចាប់ខ្លួន និងធ្វើការចោទប្រកាន់ : ហេតុដូច្នេះហើយ ការនេះបង្ហាញថា ប៉ូលិសនៅពីលើច្បាប់ ការផ្តន្ទាទោសបែបនេះ ត្រូវបានអនុញ្ញាត និងបណ្តោយអោយមានជាផ្លូវការ ហើយវាអាចត្រូវបាន

កំណត់ដាក់ទោសលើជនណាម្នាក់ ជាជាងអោយទៅតុលាការ ជាពិសេសដោយសារតែពុំមានវិធានការវិន័យលើមន្ត្រីប៉ូលិសទាំងនោះដែលមានការពាក់ព័ន្ធ ។

វាមានសារៈសំខាន់ណាស់ ដែលថាអំណាចនៃច្បាប់ត្រូវបានអនុវត្តន៍ក្នុងការដោះស្រាយអំពើហិង្សាបែបនេះនោះ ។ មានតំរូវការចាំបាច់ជាក់ស្តែងមួយតំរូវអោយមានវិធានការដោយប្រសិទ្ធភាពសំរាប់បញ្ឈប់ និងការពារកុំអោយមានការរួមគំនិតពីប៉ូលិស ឬអ្នកដ៏ទៃទៀត នៅក្នុងតួនាទីនៃអំណាច ។ រាល់ឧប្បត្តិហេតុទាំងអស់របស់ហ្វូងមហាជន ចាំបាច់ត្រូវតែធ្វើការស៊ើបអង្កេតអោយបានហ្មត់ចត់ដោយមានអធិការកិច្ចជាក់លាក់មួយ ដើម្បីសំរេចថាតើមានការខិតខំព្យាយាមធ្វើអន្តរាគមន៍ណាមួយត្រូវបានធ្វើរួចមកហើយឬទេ ។ អ្នកស៊ើបអង្កេតពីខាងក្រៅដែលពុំមានការពាក់ព័ន្ធនឹងសហគមន៍ដែលមានបញ្ហា អាចជាផ្នែកមួយនៃការស៊ើបអង្កេតបែបនោះ ។ វិធានការវិន័យ គួរតែត្រូវបានធ្វើឡើងចំពោះមេមន្ត្រី ឬមន្ត្រីណាដែលធ្វេសប្រហែសក្នុងការការពារមិនអោយមានអំពើហ្វូងមហាជន ព្រមទាំងមានធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋយ៉ាងហ្មត់ចត់ចំពោះអ្នកទាំងឡាយណាដែលទទួលខុសត្រូវក្នុងការពង្រឹងច្បាប់ ត្រូវបានសង្ស័យថា បានចូលរួមផ្សំគំនិត ។

សេចក្តីថ្លែងការណ៍ចំពោះការប្តេជ្ញាចិត្តខាងនយោបាយ ក៏អាចមានឥទ្ធិពលជាវិជ្ជមានផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ក៏វាជាការសំខាន់ណាស់ ដែលថាសេចក្តីថ្លែងការណ៍បែបនេះ ត្រូវមានគាំទ្រជាសកម្មភាពជាបន្តបន្ទាប់ដ៏ត្រឹមត្រូវ និងប្រសិទ្ធភាព ទៅលើផ្នែកតុលាការ និងប៉ូលិស ។ ដូចដែលបានបង្ហាញពីខាងដើម សេចក្តីថ្លែងការណ៍របស់អភិបាលក្រុងភ្នំពេញ លោក ជា សុផារ៉ា កាលពីខែ កុម្ភៈ ឆ្នាំ ២០០០ ពិតជាមានឥទ្ធិពលក្នុងការកាត់បន្ថយអំពើហិង្សារបស់ហ្វូងមហាជន ។ ប៉ុន្តែពុំបានជោគជ័យពេលក្រោយពីនោះមក តាមរយៈកម្មវិធីប្តេជ្ញាចិត្តនៃការពង្រឹងច្បាប់បែបនោះដោយប៉ូលិស និងតុលាការ ដើម្បីធ្វើអោយប្រាកដថាមានប្រសិទ្ធភាព សំរាប់រយៈពេលយូរអង្វែង ។ កិច្ចខិតខំប្រឹងប្រែងក្នុងពេលអនាគតដោយអាជ្ញាធរ គួរតែធ្វើឱ្យបានខ្លាំងចំពោះតំរូវការទាំងពាក្យសំដី និង សកម្មភាពដែលបានប្តេជ្ញា ។

មេដឹកនាំសាសនាមានតួនាទីដ៏សំខាន់ក្នុងការពង្រឹងនូវសារនេះ ។ សារមួយត្រូវបានបោះពុម្ពផ្សាយក្នុងខែតុលា ឆ្នាំ ២០០០ ក្នុងកាសែត "ភ្នំពេញប៉ុស្តិ៍" ដោយព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ដែលព្រះអង្គបានបញ្ជាក់ថា ការសំលាប់មនុស្សគឺវាខុសនឹងប្រពៃណីខ្មែរ និងថ្កោលទោសយ៉ាងខ្លាំងដោយវិន័យនៃព្រះពុទ្ធសាសនា ។ នៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ១៩៩៩ ការសំលាប់របស់ហ្វូងមហាជនលើរូប ប្រាក់ ខួង និងមិត្តភក្តិរបស់គេដែលមិនស្គាល់ឈ្មោះ នៅវត្តបុទុមវត្តី ក្នុងទីក្រុងភ្នំពេញ បានបង្ហាញអោយឃើញពីតំរូវការសំរាប់ការរំលឹកដល់រឿងទាំងនោះយ៉ាងខ្លោចផ្សា ។ ដោយកំហឹងរបស់ហ្វូងមហាជនអាចផ្តោតទៅលើមនុស្សមកពីគណបក្សនយោបាយនាមួយ ជនជាតិភាគតិច ឬប្រភពសង្គមណាមួយនោះ បញ្ហានេះក៏អាចជាប់ជំពាក់ទៅនឹងកិច្ចសហការរវាងគណបក្សនយោបាយ ។

តំរូវការសំរាប់វិធានការដែលបានប្តេជ្ញាបញ្ឈប់សកម្មភាពទាំងនេះ គឺត្រូវការជាបន្ទាន់ ។ ដោយសារតែប្រទេសជាតិឈាន ទៅរកការបោះឆ្នោតជាទូទៅមួយក្នុងឆ្នាំ ២០០៣ នីតិរដ្ឋត្រូវតែមាន ហើយកំលាំងប៉ូលិសកម្ពុជាត្រូវតែពង្រឹង និងប្រព្រឹត្តទៅតាមច្បាប់ មិនមែនធ្វើឡើងនៅក្រៅច្បាប់ទេ ។ ទោះបីជាពុំមានការទាក់ទងគ្នាគួរអោយទុកចិត្ត រវាងការសំលាប់ដោយហ្វូងមហាជន និងអំពើហិង្សា ខាងការបោះឆ្នោតក៏ដោយ ក៏លោកតំណាងពិសេសរបស់លោកអគ្គលេខាធិការ សូមរំលឹកឡើងវិញដល់រដ្ឋាភិបាល និងគ្រប់គណបក្ស នយោបាយទាំងអស់ ពីការសំលាប់នៅតាមផ្លូវលើជនជាតិភាគតិចវៀតណាមនៅទីក្រុងភ្នំពេញ ក្នុងការបោះឆ្នោតជាទូទៅមួយកាលពីឆ្នាំ ១៩៩៨ ។ អំពើបែបនេះ មិនគួរអនុញ្ញាតអោយកើតឡើងជាថ្មីម្តងទៀតទេ ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

កិច្ចខិតខំរបស់ប្រទេសកម្ពុជាដើម្បីដោះស្រាយអំពើហិង្សាដោយហ្វូងមហាជន បានបង្ហាញអោយឃើញថានៅមិនទាន់គ្រប់គ្រាន់ នៅឡើយទេ ។ ពីព្រោះតែវិធានការមិនគ្រប់គ្រាន់ ឬការពុំមានគុណភាពដើម្បីដោះស្រាយជាមួយនឹងហេតុការណ៍ដែលកើតឡើងទាំង នេះ។ ទាំងនេះ រួមមានបញ្ហាប៉ូលិសធ្វើកិច្ចការដោយឈរពីលើច្បាប់ ។ សេចក្តីថ្លែងការណ៍ពីឆន្ទៈនយោបាយ មានប្រសិទ្ធភាពវិជ្ជមាន តែក្នុងរយៈពេលខ្លី ក្នុងការកាត់បន្ថយអំពើហិង្សាដោយហ្វូងមហាជន ប៉ុន្តែត្រូវតែមានការគាំទ្រដោយកិច្ចខិតខំប្រឹងប្រែងដ៏ស្វាហាប់ ជា បន្តបន្ទាប់ទៀតដោយប៉ូលិស និងមេដឹកនាំសហគមន៍ដើម្បីធានាអោយមានដំណោះស្រាយជាប់លាប់ ។ ក្នុងការបង្កើតគោលការណ៍ ដើម្បីដោះស្រាយអំពើហិង្សាដោយហ្វូងមហាជន តំរូវការដើម្បីលើកស្ទួយស្តង់ដារនៃការពង្រឹងច្បាប់ គួរតែជាអាទិបាពដ៏ចំបងមួយ ដែល ត្រូវធ្វើ ។

ការដែលប៉ូលិសញុះញង់អោយធ្វើការវាយប្រហារបែបនេះ ឬមិនបានបញ្ជូនសំនុំរឿងទៅតុលាការ ធ្វើអោយមានបញ្ហាដ៏ធ្ងន់ធ្ងរ ជាច្រើនអំពីអាកប្បកិរិយារបស់កងកំលាំងប៉ូលិស និងបង្ហាញអោយឃើញពីភាពគ្មានការពិនិត្យមើលអោយបានសមរម្យ ។ ការនេះក៏បាន បង្ហាញអោយឃើញពីកង្វះខាតជំនឿនៅក្នុងប្រព័ន្ធតុលាការ ទាំងពីខាងផ្នែកប៉ូលិស និងពលរដ្ឋសាមញ្ញ ។

ការអះអាងដោយមន្ត្រីប៉ូលិសថា ពួកគេពុំមានអំណាចទប់ទល់នឹងហ្វូងមហាជនមួយក្រុម អាចមានការជឿជាក់ជាងនេះបាន ប្រសិនបើជាញឹកញាប់ពួកគេមិនបានរួមគំនិតទេនោះ ។ ពុំមានវិធានការណាមួយធ្វើឡើងដោយមន្ត្រីប៉ូលិស ដែលត្រូវធ្វើការស៊ើបអង្កេត អោយបានហ្មត់ចត់ និងការចោទប្រកាន់បទព្រហ្មទណ្ឌ ឬខាងវិន័យធ្វើឡើងចំពោះអ្នកដែលមានភស្តុតាងបង្ហាញពីការធ្វេសប្រហែស ឬ ចរិយាមិនគប្បីផ្សេងទៀតនោះទេ ។

ការពិនិត្យតាមដានយ៉ាងជិតស្និទលើសកម្មភាពរបស់ប៉ូលិសក្នុងការពាក់ព័ន្ធនឹងអំពើហិង្សាដោយហ្វូងមហាជន គឺមានសារៈសំខាន់ ខ្លាំងណាស់ ។ ក្រសួងមហាផ្ទៃ និងនាយកដ្ឋាននគរបាល មានតួនាទីដ៏សំខាន់មួយក្នុងកិច្ចការនេះ ។ ការពិនិត្យមើលដ៏ប្រសិទ្ធភាព

អាចជួយធ្វើអោយប្រាកដថា ប៉ូលិសមិនប្រព្រឹត្តអ្វីពីលើច្បាប់ និងថាឯកសារប៉ូលិសកត់ត្រាទុកបានយ៉ាងហ្មត់ចត់ត្រូវបានចងក្រងទុក និងបញ្ជូនទៅតុលាការ ។

បទបញ្ញាតិរបស់ច្បាប់អង្គការសហប្រជាជាតិស្តីពីការប្រព្រឹត្តរបស់មន្ត្រីពង្រឹងច្បាប់ គួរតែត្រូវបានធ្វើអោយសមាជិកទាំងអស់នៃកងកំលាំងប៉ូលិសកម្ពុជាបានដឹង និងត្រូវបានពង្រឹង ។ មាត្រា ទី ២ ៥ ៦ និង ៨ នៃឯកសារនេះ ដែលសំដៅទៅលើសេចក្តីត្រូវការសំរាប់ជនសង្ស័យ ត្រូវបានការពារឱ្យផុតពីការធ្វើមិនគប្បីទៅលើខ្លួន និងសំរាប់មន្ត្រីពង្រឹងច្បាប់ដើម្បីការពារកុំអោយមានការរំលោភច្បាប់មានថែងនៅក្នុងច្បាប់នេះ ។

ព្រះរាជអាជ្ញាចាំបាច់ត្រូវបញ្ជាក់ពីការខ្វះខាតរបស់ខ្លួន និងសាកសួរថាតើហេតុអ្វីបានជាប៉ូលិស និងហ្វូងមហាជនត្រូវបានអនុញ្ញាតអោយប្រព្រឹត្តល្មើសច្បាប់ ហើយហេតុអ្វីបានជាគេមិនត្រូវបានកាត់ទោស ព្រមទាំងហេតុអ្វីបានជាដំណើរការតាមផ្លូវច្បាប់មិនត្រូវបានយកមកអនុវត្តន៍ ។ វិធានការចាំបាច់ត្រូវតែធ្វើដើម្បីធានាអោយប្រាកដថា អ្នកទាំងនោះដែលទទួលខុសត្រូវលើសកម្មភាពនៃអំពើហិង្សាដោយហ្វូងមហាជន ត្រូវបានដោះស្រាយដោយយោងទៅតាមច្បាប់ពេញលេញផ្ទាល់របស់ប្រទេសកម្ពុជា ក៏ដូចជាសន្ធិសញ្ញាអន្តរជាតិដ៏ទៃទៀត ដែលកម្ពុជាមានកាតព្វកិច្ចជាផ្លូវច្បាប់ត្រូវគោរព ។

ពលរដ្ឋកម្ពុជាភាគច្រើនចាំបាច់ត្រូវតែចោទសួរថាតើ ហេតុអ្វីបានពួកគេមិនមានប្រតិកម្មចំពោះអំពើហិង្សាដោយហ្វូងមហាជនដែលប្រកបដោយការគួរអោយអាម៉ាស់ និងភ័យខ្លាច ដោយសារតែការសំលាប់មនុស្សវាផ្ទុយទៅនឹងប្រពៃណីខ្មែរ និងទស្សនៈព្រះពុទ្ធសាសនា ហើយហេតុអ្វីបានជាពួកគេមិនខិតខំធ្វើអោយបាន ច្រើនជាងនេះដើម្បីធ្វើអោយអាជ្ញាធរបំពេញតួនាទី ។

គណៈកម្មការស៊ើបអង្កេតឯករាជ្យមួយ ដែលមានអ្នកតំណាងទទួលខុសត្រូវមកពីគ្រប់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងអង្គការសាសនានានា គួរត្រូវបានបង្កើតអោយបានឆាប់ ដើម្បីពិនិត្យមើលការប្រព្រិត្តរបស់ប៉ូលិស និងព្រះរាជអាជ្ញាក្នុងការសំលាប់ដោយហ្វូងមហាជនទាំងអស់ ។ គណៈកម្មការនេះគួរមានអំណាចផ្តល់អនុសាសន៍ជាវិធានការវិន័យ ឬព្រហ្មទណ្ឌ ។

លោកតំណាងពិសេស សូមរំលឹកសមាជិកទាំងអស់នៃសង្គមថា មនុស្សគ្រប់រូបមានជាប់មកជាមួយនូវសិទ្ធិរស់រានមានជីវិត ។ សិទ្ធិនេះត្រូវតែការពារដោយច្បាប់ ។ គ្មាននរណាម្នាក់ត្រូវបានដកហូតនូវជីវិតរបស់ពួកគេតាមទំនើងចិត្តនោះទេ។

---

**ឧបសម្ព័ន្ធ :** ដំណើរបន្តគ្នាដូចខាងក្រោមនេះបានបង្ហាញពីការសំលាប់លើ សុង វ៉ាសនា និង ឌី ហួរ កាលពីថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២000 នៅក្នុងទីក្រុងភ្នំពេញ ។ អ្នកទាំងពីរនាក់ត្រូវបានចាប់ខ្លួនដោយមានការសង្ស័យពីបទប្លន់ ។ វ៉ាសនា ត្រូវបានប្រគល់អោយទៅហ្វូងមហាជនមួយក្រុមដែលបានសំលាប់គាត់ ។ ឌី ហួរ ត្រូវបានយកចេញឆ្ងាយហើយក្រោយមកត្រូវបានបាញ់ស្លាប់ ។ ពុំមានវិធានការវិន័យ ឬព្រហ្មទណ្ឌត្រូវបានដឹងថា បានធ្វើឡើងចំពោះអ្នកពាក់ព័ន្ធណាម្នាក់ ក្នុងចំណោមពួកគេទាំងនោះទេ ។

១. ប៉ូលិសបានឃុំខ្លួន វ៉ាសនា មួយរយៈពេលខ្លី បន្ទាប់មកបាននាំខ្លួនគេត្រឡប់ទៅកាន់កន្លែងចាប់ខ្លួនវិញ ជាកន្លែងដែលក្រុមហ្វូងមហាជនចាប់ផ្តើមវាយរូបគេ ។ មន្ត្រីប៉ូលិសម្នាក់ដែលនៅពីក្រោយខ្នង វ៉ាសនា ដែលមើលទៅដូចជារឹតបណ្តឹងដៃរបស់ វ៉ាសនា ។



២. កំណាត់ឈើ និងការទាត់ធាក់ត្រូវបានប្រើប្រាស់ដើម្បីធ្វើអោយមានការហូរឈាមដ៏ធ្ងន់ធ្ងរ ។ វ៉ាសនា បានសន្លប់បាត់ស្មារតី ។



៣. បន្ទាប់ពីបានដុតលើរាងកាយរបស់វាសនា ហ្វូងមហាជនក៏ចែកផ្លូវចាកចេញទៅរៀងៗខ្លួន ។



៤. ឌី ហួរ ត្រូវបានដាក់នៅក្នុងឡានប៉ូលិសមួយ ។ គាត់ត្រូវបានដឹកដោយឡានចេញទៅក្រៅហើយត្រូវបានបាញ់ស្លាប់ដោយ ប៉ូលិស ដែលនិយាយថា ជនរូបនេះបានព្យាយាមរត់គេចខ្លួន ។

